**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**លេខៈ** ១៥៩ ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើតក្រុមការងារប្រព័ន្ធផ្សព្វផ្សាយសង្គមថ្មី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ៩១ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការបង្កើតអង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស
- តាមសំណើរបស់ប្រធានអង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស

**សម្រេច**

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារប្រព័ន្ធផ្សព្វផ្សាយសង្គមថ្មី សរសេរអក្សរកាត់ (ក.ប.ផ.ថ) ជាភាសាអង់គ្លេសហៅថាៈ Cyber War Team សរសេរកាត់ (CWT) ចំណុះឲ្យអង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស ដើម្បីតាមដាន និងជំរុញការផ្សព្វផ្សាយព័ត៌មានរបស់រាជរដ្ឋាភិបាល និងរដ្ឋបាលសាធារណៈ តាមប្រព័ន្ធផ្សព្វផ្សាយសង្គមថ្មី ដូចជា គេហទំព័រ Face book Twitter, Pages, Google-plus, blog, YouTube និងប្រព័ន្ធផ្សព្វផ្សាយដទៃទៀត ឲ្យបានទូលំទូលាយជូនប្រជាពលរដ្ឋឲ្យទាន់ពេលវេលាស្របតាមច្បាប់ និងការវិវត្តរបស់សង្គមជាតិ។

**ប្រការ ២.-**

ក.ប.ផ.ថ មានបេសកកម្ម តួនាទី និងភារកិច្ច ដូចតទៅៈ

- ស្រាវជ្រាវ ប្រមូល វិភាគ និងចងក្រងព័ត៌មានជាតិ និងអន្តរជាតិ គ្រប់រូបភាពដើម្បីជាមូលដ្ឋានក្នុងការបកស្រាយ និងបំភ្លឺជូនសាធារណៈជនសំដៅការពារជំហរ និងកិត្យានុភាពរបស់រាជរដ្ឋាភិបាល
- រៀបចំផែនការសកម្មភាព ផែនការយុទ្ធសាស្ត្រ ផែនការការងារ និងយុទ្ធវិធីទៅតាមវិស័យ និងគោលដៅផ្សព្វផ្សាយព័ត៌មានរបស់ខ្លួន
- អនុវត្តផែនការសកម្មភាព ផែនការយុទ្ធសាស្ត្រ ផែនការការងារ និងយុទ្ធវិធីរបស់ ក.ប.ផ.ថ ដែលបានដាក់ចុះដើម្បីផ្សព្វផ្សាយទប់ស្កាត់ បំភ្លឺ និងការពាររាល់សកម្មភាព និងសមិទ្ធផលរបស់រាជរដ្ឋាភិបាល
- ពង្រីកសកម្មភាពផ្សព្វផ្សាយព័ត៌មាន និងសហការជាមួយក្រសួងស្ថាប័ន អាជ្ញាធរ អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- តាមដាន ត្រួតពិនិត្យការវិវត្តយន្តការ និងចរិតលក្ខណៈនៃការផ្សព្វផ្សាយព័ត៌មាន
- រៀបចំការបណ្តុះបណ្តាលសមត្ថភាពមន្ត្រីរាជការ អំពីការវិវឌ្ឍនៃបច្ចេកវិទ្យាថ្មីៗ
- បំពេញភារកិច្ចផ្សេងទៀត តាមការប្រគល់ជូនរបស់អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស។

**ប្រការ ៣.-**

ក.ប.ផ.ថ ត្រូវដឹកនាំដោយប្រធាន១រូប អមដោយអនុប្រធានមួយចំនួន និងមានសមាជិក តាមការចាំបាច់។

ការតែងតាំងសមាសភាពនៃក.ប.ផ.ថ ត្រូវធ្វើឡើងតាមសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី តាមសំណើរបស់ប្រធានអង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស។

**ប្រការ ៤.-**

ក.ប.ផ.ថ មានលេខាធិការដ្ឋានរបស់ខ្លួនមួយ ដែលជាសេនាធិការរដ្ឋបាល ។

លេខាធិការដ្ឋាន ត្រូវដឹកនាំដោយប្រធានមួយរូបដែលមានឋានៈស្មើប្រធាននាយកដ្ឋាន និងអមដោយអនុប្រធានមួយចំនួនតាមការចាំបាច់ ដែលមានឋានៈស្មើ អនុប្រធាននាយកដ្ឋាន។

**ប្រការ ៥.-**

លេខាធិការដ្ឋាន ក.ប.ផ.ថ មានតួនាទី និងភារកិច្ច ដូចខាងក្រោមៈ

- វិភាគ និងគ្រប់គ្រង ត្រួតពិនិត្យ តាមដានជំរុញការអនុវត្តរបស់ផ្នែកនីមួយៗ
- សិក្សាស្រាវជ្រាវ សរុបព័ត៌មាន និងកសាងមូលដ្ឋានទិន្នន័យ
- លើកផែនការបណ្តុះបណ្តាលមន្ត្រីរាជការ តាមការចាំបាច់
- ចាត់ចែងការងាររដ្ឋបាល បម្រើឲ្យការដំណើរការការងាររបស់ ក.ប.ផ.ថ
- រៀបចំរបាយការណ៍ កំណត់ហេតុរដ្ឋបាល និងសម្របសម្រួលកិច្ចការផ្គត់ផ្គង់ និងហិរញ្ញវត្ថុ
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់របស់ថ្នាក់ដឹកនាំអង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស។

**ប្រការ ៦.-**

លេខាធិការដ្ឋាន នៃ ក.ប.ផ.ថ មានផ្នែកចំណុះចំនួន ៦ ដូចខាងក្រោម៖

១. ផ្នែក តាមដាន

២. ផ្នែក ផ្តួចផ្តើមគំនិត

៣. ផ្នែក ត្រួតពិនិត្យ

៤. ផ្នែក ផ្សព្វផ្សាយ និង កសាងបណ្តាញ

៥. ផ្នែក បច្ចេកទេស

៦. ផ្នែក ចងក្រងទិន្នន័យ

**ប្រការ ៧.-**

ផ្នែក តាមដាន មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- តាមដានព័ត៌មានគ្រប់ប្រភេទ និងគ្រប់វិស័យ
- កំណត់ប្រធានបទ ដែលត្រូវវាយការណ៍ និងដែលត្រូវឆ្លើយតប
- លើកគំនិត យោបល់ ដើម្បីផលិត ដោយឈរលើព័ត៌មានដែលទទួលបាន និងក្រោយពីមានការវាយតម្លៃច្បាស់លាស់
- អនុវត្តការងារដទៃទៀត ដែលថ្នាក់ដឹកនាំអង្គភាព ប្រគល់ឲ្យ។

**ប្រការ ៨.-**

ផ្នែកផ្តួចផ្តើមគំនិត មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ផ្តួចផ្តើម បំផុស ស្វែងរក និងប្រមូលផ្តុំគំនិត យោបល់ ដើម្បីផលិត បម្រើឲ្យការផ្សព្វផ្សាយតាមគ្រប់រូបភាព
- អនុវត្តការងារដទៃទៀត ដែលថ្នាក់ដឹកនាំអង្គភាព ប្រគល់ឲ្យ។

**ប្រការ ៩.-**

ផ្នែកត្រួតពិនិត្យ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ត្រួតពិនិត្យការអនុវត្តការងាររបស់ផ្នែកនីមួយៗ ទៅសង្វាក់ផលិតកម្មដែលបានប្រគល់ឲ្យ
- គ្រប់គ្រង ត្រួតពិនិត្យការផ្សព្វផ្សាយ និងការពង្រីកបណ្តាញផ្សព្វផ្សាយតាមគ្រប់រូបភាពតាមប្រព័ន្ធផ្សព្វផ្សាយសង្គមថ្មី ដើម្បីធានាថា ផលិតផលដែលបានផលិត ត្រូវបានផ្សព្វផ្សាយដល់គោលដៅ និងបានទូលំទូលាយ
- ត្រួតពិនិត្យ តាមដានការផ្សព្វផ្សាយព័ត៌មានគ្រប់រូបភាពពីប្រភពផ្សេងៗ
- អនុវត្តការងារដទៃទៀត ដែល ថ្នាក់ដឹកនាំអង្គភាព ប្រគល់ឲ្យ។

**ប្រការ ១០.-**

ផ្នែកកសាងបណ្តាញ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- បង្ហោះ និងផ្សព្វផ្សាយនូវព័ត៌មានដែលបានផលិត និងសម្រេចរួចហើយ ទៅកាន់បណ្តាញផ្សព្វផ្សាយព័ត៌មានដទៃទៀត

- ទំនាក់ទំនងអង្គភាព ស្ថាប័ន ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីពង្រីកបណ្តាញ
- អនុវត្តការងារដទៃទៀត ដែល ថ្នាក់ដឹកនាំអង្គភាព ប្រគល់ឲ្យ។

**ប្រការ ១១.-**

ផ្នែក បច្ចេកទេស មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ទទួលខុសត្រូវលើការងារបច្ចេកទេស ក្នុងការផលិត
- គ្រប់គ្រងសុវត្ថិភាពបណ្តាញ
- បង្កើតកម្មវិធី តាមការវិវត្តរបស់បច្ចេកវិទ្យាព័ត៌មាន
- បង្កើត និងអភិវឌ្ឍយន្តការផ្សព្វផ្សាយព័ត៌មាន ឲ្យបានច្រើនរូបភាព និងឲ្យកាន់តែទូលំទូលាយ
- អនុវត្តការងារដទៃទៀត ដែលថ្នាក់ដឹកនាំអង្គភាព ប្រគល់ឲ្យ។

**ប្រការ ១២.-**

ផ្នែកចងក្រងទិន្នន័យ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- កសាងមូលដ្ឋានទិន្នន័យដើម្បីរក្សាទុកជាឯកជាសារ និងព័ត៌មានគ្រប់រូបភាពដែលបានប្រមូលទុក និងដែលបានផលិតជាផ្លូវការ
- ជាមជ្ឈមណ្ឌលផ្តល់ទិន្នន័យដល់ផ្នែកផ្សេងៗ
- អនុវត្តការងារដទៃទៀត ដែលថ្នាក់ដឹកនាំអង្គភាព ប្រគល់ឲ្យ។

**ប្រការ ១៣.-**

ផ្នែកនីមួយៗ ដឹកនាំដោយប្រធាន១ រូប មានឋានៈស្មើប្រធានការិយាល័យ អមដោយអនុប្រធាន មួយចំនួន តាមការចាំបាច់ ដែលមានឋានៈស្មើអនុប្រធានការិយាល័យ។

**ប្រការ ១៤.-**

ក.ប.ផ.ថ មានថវិការបស់ខ្លួនសម្រាប់ដំណើរការ ដែលជាថវិកាឧបសម្ព័ន្ធរបស់អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស។

**ប្រការ ១៥.-**

របៀបរបបការងាររបស់ ក.ប.ផ.ថ ត្រូវកំណត់ដោយប្រធានអង្គភាពព័តមាន និងប្រតិកម្មរហ័ស។

**ប្រការ ១៦.-**

អគ្គលេខាធិការរាជរដ្ឋាភិបាល ប្រធានអង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធាននាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច ប្រធាននាយកដ្ឋានបុគ្គលិក គ្រប់អង្គភាពពាក់ព័ន្ធ

ក្រោមឱវាទទីស្ដីការគណៈរដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ១០ ឆ្នាំ២០១៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**ស៊ុខ អាន**

**កន្លែងទទួល**

- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ដូចប្រការ ១៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ